01359029



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 12 / 2016
ម៉ោង (Time/Heure) : 15:06
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ២៩ ខែ សីហា ឆ្នាំ ២០១៦

## សវនាការលើកស្តុតាង - ថ្ងៃ ៤៤៦

រៀបចំដោយ៖ លោកស្រី សែ គុលវុឌ្ឍី និង កញ្ញា Stavroula PAPADOPOULOS

| **កំណត់ហេតុអ្នកចូលរួម** |
| --- |
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ, ចៅក្រម ធួ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin Karopkin |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុលវុឌ្ឍី, កញ្ញា Stavroula PAPADOPOULOS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ស្រ៊ា រតនៈ, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក លើវ សុវណ្ណា, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោកស្រី Anta GUISSÉ, លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោកស្រី ស៊ិន សូវ៉ន, លោក ហុង គីមសួន, លោក ឡោ ជុនធី |
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ លោក សេង សឿន (2-TCCP-219) |

| |
|---|
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ និង លោកស្រី សួរ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, កញ្ញា ស្រី ណាក់, លោក វ៉ាត សុម៉ៅ, លោក ឡូញ ង៉េត, កញ្ញា យស់សេរីរត្ន័, លោក សុខ សុភ័ក្រ, កញ្ញា Elodie KANCEL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៣ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៥ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣២ | បញ្ចប់ម៉ោង៖ ១៤.៤៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២៦ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០០ | ០៩.០១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | អង្គជំនុំជម្រះ | ០៩.០១ | ០៩.០៣ |
| ការកត់សម្គាល់របស់ភាគីទាក់ទងនឹងការស្តាប់សក្ខីកម្មសាក្សី 2-TCW-1002 នៅក្នុងសវនាការជាអសាធារណៈ | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៥<br>០៩.០៦<br><br>០៩.០៦<br>០៩.០៦ | ០៩.០៦<br>០៩.០៦<br><br>០៩.០៦<br>០៩.០៧ |
| សេចក្តីសម្រេចផ្ទាល់មាត់តាមវិធាន ៨៧ (៣) និង ៨៧ (៤) សំណើរបស់មេធាវីការពារក្តី នួន ជា ឲ្យទទួលយកជាឯកសារភស្តុតាង | អង្គជំនុំជម្រះ | ០៩.០៩ | ០៩.១៣ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន (2-TCCP-219) | អង្គជំនុំជម្រះ<br>មេធាវីនាំមុខតំណាងឲ្យដើម | ០៩.១៤<br>០៩.២២ | ០៩.២២<br>១០.១៥ |

| | | | |
|---|---|---|---|
| | បណ្តឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | <br>១០.៣៦<br>១៤.៥៩<br>១៥.០០ | <br>១៤.៣២<br>១៥.០០<br>១៦.០០ |
| ការជំទាស់ចំពោះការតាំងសំណួរដោយសហព្រះរាជអាជ្ញា | មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ | ១៣.៣៦<br>១៣.៣៧ | ១៣.៣៦<br>១៣.៣៧ |
| ការជំទាស់ចំពោះការតាំងសំណួរដោយសហព្រះរាជអាជ្ញា | មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ | ១៣.៥៨<br>១៣.៥៩ | ១៣.៥៨<br>១៣.៥៩ |
| ការជំទាស់ចំពោះការតាំងសំណួរដោយសហព្រះរាជអាជ្ញា | មេធាវីការពារក្តី នួន ជា<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១៤.២៧<br>១៤.២៨<br>១៤.២៩ | ១៤.២៧<br>១៤.២៨<br>១៤.២៩ |
| ការជំទាស់ចំពោះការតាំងសំណួរដោយមេធាវីការពារក្តី នួន ជា | សហមេធាវីនាំមុខ<br>មេធាវីការពារក្តី ខៀវ សំផន<br>មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ | ១៥.៣០<br>១៥.៣១<br>១៥.៣២<br>១៥.៣៣ | ១៥.៣១<br>១៥.៣២<br>១៥.៣៣<br>១៥.៣៣ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការកត់សម្គាល់របស់ភាគីទាក់ទងនឹងការស្តាប់សក្ខីកម្មសាក្សី 2-TCW-1002 ក្នុងសវនាការជាអសាធារណៈ</u>**

អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីទាក់ទងនឹងការស្តាប់សក្ខីកម្មសាក្សី 2-TCW-1002 នៅក្នុងសវនាការជាអសាធារណៈ។ សហព្រះរាជអាជ្ញា មិនបានជំទាស់ទៅនឹងសំណើសុំក្នុងការស្តាប់សក្ខីកម្មសាក្សីនេះនៅក្នុងសវនាការជាអសាធារណៈនោះទេ។ មេធាវីនាំមុខ មេធាវីការពារក្តី នួន ជា និង

មេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ថាមិនមានការកត់សម្គាល់ពីបញ្ហានេះទេ។ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះចេញសេចក្ដីសម្រេចពីបញ្ហានេះឱ្យបានឆាប់។

**<u>សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង</u>**

អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្ដី នួន ជា បានដាក់សំណើជាលាយលក្ខណ៍អក្សរតាមវិធាន ៨៧(៤) នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ សុំឱ្យទទួលយកឯកសារចំនួនបួនធ្វើជាឯកសារភស្តុតាង (ឯកសារ E430)។ ឯកសារចំនួនពីរក្នុងចំណោមឯកសារទាំងនោះត្រូវបានទទួលយក តាមរយៈសេចក្ដីសម្រេចផ្ទាល់មាត់ចេញនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។ នាពេលនេះ អង្គជំនុំជម្រះសូមលើកយកមកដោះស្រាយផ្នែកផ្សេងទៀតនៃសំណើសុំ ដែលមេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យទទួលយកសេចក្ដីដកស្រង់ចេញពីឯកសារ E319/45.4.8 ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-286 ដែលត្រូវបានកំណត់ឱ្យមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែក។ ទោះបីជាឯកសារ E430 យោងទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-28 ក៏ដោយ តែព័ត៌មានផ្សេងទៀតនៅក្នុងសំណើសុំនេះបង្ហាញច្បាស់ថា មេធាវីការពារក្ដីមានបំណងយោងទៅដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-286។

អង្គជំនុំជម្រះកត់សម្គាល់ថា ផ្នែកមួយនៃឯកសារ E319/45.4.8 ដែលបានស្នើសុំ មាននៅក្នុងឯកសារ E3/5010 ដែលត្រូវបានទទួលយកធ្វើជាឯកសារភស្តុតាងរួចហើយ ដែលឯកសារនោះក៏ជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-286 ដែរ។ សេចក្ដីដកស្រង់ដែលមេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យទទួលយកគឺជាផ្នែកបន្ថែមនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើង។ អង្គជំនុំជម្រះកត់សម្គាល់ថា មានកំហុសឆ្គងចំពោះលេខ ERN មួយចំនួនដែលបានលើកឡើងនៅក្នុងសំណើសុំនេះ ហេតុដូច្នេះ ក្នុងការចេញសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសូមសំអាងទៅលើសេចក្ដីដកស្រង់ដែលមានភ្ជាប់ជាមួយនឹងឯកសាររបស់មេធាវីការពារក្ដីជំនួសវិញ។

អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកដល់ការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកចម្លើយពីមុនៗរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬ សាក្សីដែលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ធ្វើជាឯកសារភស្តុតាង អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ វាជាប្រយោជន៍នៅក្នុងការស្វែងរកការពិត ដែលថាអង្គជំនុំជម្រះ និងភាគីអាចចូលពិនិត្យមើលចម្លើយទាំងអស់របស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២។

ហេតុនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់មេធាវីការពារក្ដី នួន ជា ដែលស្នើសុំឱ្យទទួលយកសេចក្ដីដកស្រង់ដែលបានស្នើសុំពីឯកសារ E319/45.4.11 ដែលមាននៅក្នុងឯកសារ E430.2 និងឯកសារ E430.4 ធ្វើជាឯកសារភស្តុតាង។ អង្គជំនុំជម្រះដាក់លេខសំគាល់ E3/5010B សម្រាប់សេចក្ដីដកស្រង់ទាំងអស់នេះ។

**<u>ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន</u>** <u>(2-TCCP-219)</u>

អង្គជំនុំជម្រះ មេធាវីនាំមុខតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី នួន ជា បានតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន (2-TCCP-219)។

**<u>ការជំទាស់ដោយមេធាវីការពារក្ដី នួន ជាចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញាទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន</u>** <u>(2-TCCP-219)</u>

មេធាវីការពារក្ដី នួន ជា បានជំទាស់ចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញាទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ដោយលើកឡើងថា សំណួរនោះជាសំណួរនាំមុខ។ អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតិឱ្យសហព្រះរាជអាជ្ញា បន្តតាំងសំណួរនោះទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**<u>ការជំទាស់ដោយមេធាវីការពារក្ដី ខៀវ សំផន ចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញាទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន</u>** <u>(2-TCCP-219)</u>

មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់ចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញាទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ដោយលើកឡើងថា សំណួរងាកចាកឆ្ងាយពីអង្គហេតុនៃបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះ បានសម្រេចអនុញ្ញាតិឱ្យសហព្រះរាជអាជ្ញាបន្តតាំងសំណួរនោះទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**<u>ការជំទាស់ដោយមេធាវីការពារក្ដី នួន ជាចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញាទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន</u>** <u>(2-TCCP-219)</u>

មេធាវីការពារក្ដី នួន ជា បានជំទាស់ចំពោះសហព្រះរាជអាជ្ញាក្នុងការដកស្រង់ពីឯកសារ E1/206.1 ដោយលើកឡើងថា "ការដកស្រង់ភស្តុតាងនេះ គឺវានៅក្រៅបរិបថទាំងស្រុង"។ សហព្រះរាជអាជ្ញា បានឆ្លើយតបថា មេធាវីការពារក្ដី ក៏បានសួរតទល់ជាមួយសាក្សី ដោយប្រើប្រាស់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែរ។ អង្គជំនុំជម្រះ បានសម្រេចបដិសេធការជំទាស់ ហើយអនុញ្ញាតិឱ្យសហព្រះរាជអាជ្ញាតាំងសំណួរនោះទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**<u>ការជំទាស់ដោយមេធាវីនាំមុខ ចំពោះការតាំងសំណួររបស់មេធាវីការពារក្ដី នួន ជា ទៅដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន</u>** <u>(2-TCCP-219)</u>

មេធាវីនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានជំទាស់ចំពោះការតាំងសំណួរដោយមេធាវីការពារក្តី នួន ជា ដែលសួរសំណួរនាំមុខ។ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យមេធាវីការពារក្តី សួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។

New E3s

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/409 | D232/59 | 00402505-00402517; 00412176-00412187; 00434539-00434551 | [Corrected 1] Written Record of Interview of SENG Soeun | P | 00402507; 00402509; 00402511; 00402512; 00402513; 00402515; 00402516; | 00412178; 00412180; 00412181; 00412182; 00412183; 00412185; 00412186; | 00434541; 00434543; 00434545; 00434546; 00434549; 00434550; |
| E3/5643 | E190.1.405 | 00059307-00059407; 00753814-00753900; 00756558-00756651 | Interview with TCCP-142 | P | 00059318; 00059327; 00059348; 00059360-00059361; 00059380; 00059381; 00059402; | 00753825; 00753835; 00753854; 00753864; 00753878; 00753879; 00753896; | 00756568; 00756577; 00756596; 00756607-00756608; 00756626; 00756647; |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9833 | E319/28.3.17 | 01095235-01095269; 01111826-01111849; - | [Corrected 1] Written Record of Interview witness MUOL Eng | C | 01095267; 01095268 | 01111848 | - |
| E3/1094 | - | 00143603-00143617; 00315368-00315383; 00593523-00593538 | To respected Angkar from M401 | P | 00143610; 00143617; | 00315374; 00315383; | 00593530; 00593538; |
| E3/1651 | D108/26.280 | 00086824-00086836; 00789497-00789512; 00841421- | S-21 Prisoner List containing names of prisoners interrogated at S-21 | P | 00086832; 00086833-00086834; | 00789507; 00789508-00789510; | 00841431; 00841432-00841434; |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00841436 | | | | | |
| E3/746 | - | 00064485-00064511; 00428289-00428307; 00611870-00611892 | CPK Magazine entitled: "The Revolutionary Flag", Issue 7, July 1978 (FULL) | P | 00064495 | 00428297 | 00611878 |
| E3/765 | D248/4.10 | 00376472-00376507; 00539976-00540007; 00540008-00540037 | Revolutionary Youth Number 10 October 1978 | P | 00376493-00376494 | 00539994 | 00540024-00540025 |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៣)
- សម្រេចលើសំណើរបស់មេធាវីការពារក្ដី នួន ជា អនុលោមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុងសុំឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-286 ជាឯកសារភស្តុតាង។ (០៩.០៩ ដល់ ០៩.១៣)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃ អង្គារ៍ ទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ។ (១៦.០២)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃអង្គារ៍ ទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ [illegible] លោក[illegible] Stavroula PAPADOPOULOS